ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**
**គណៈកម្មាធិការលទ្ធកម្ម**
**លេខ : ១១/១៦**

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញចូលរួមដេញថ្លៃ ការងារជួសជុលផ្លូវរត់ទំហំ ១០.១១០ម$^2$
## នៅអាកាសយានដ្ឋានបាត់ដំបង

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានជ្រាបថា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការងារធ្វើការងារជួសជុលផ្លូវរត់ ទំហំ ១០.១១០ម$^2$ នៅអាកាសយានដ្ឋានបាត់ដំបង ។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលមានអាសយដ្ឋានលេខៈ ៦២, មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១៦ តទៅ រៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខៈ ០២៣ ២១៦ ៦៤៩)។

ឯកសារដេញថ្លៃ ដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី០៧ខែ វិច្ឆិកា ឆ្នាំ ២០១៦ វេលាម៉ោង: ១៥:០០ ។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង: ១៥:៣០ ថ្ងៃទី០៧ខែវិច្ឆិកា ឆ្នាំ ២០១៦ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី...១៧...ខែ...កញ្ញា...ឆ្នាំ២០១៦

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ម៉ៅ ហាវណ្ណាល់**

ចម្លងជូន ៖
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ